ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី

ក្រុមអ្នកនាំពាក្យ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលជំនួបរវាងសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោក Lin Baifeng ប្រធានក្រុមហ៊ុន Huawei ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក

នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យ **លោក Lin Baifeng ប្រធានក្រុមហ៊ុន Huawei** ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានសន្តិភាព។

ក្នុងឱកាសនៃជំនួប **លោក Lin Baifeng** បានលើកឡើងថា កម្ពុជាជាប្រទេសមួយដែលមានសុខសន្តិភាពពេញលេញបរិបូរណ៍ រក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ប្រកបដោយភាពធន់ ដែលការណ៍នេះបានក្លាយទៅជាបុរេលក្ខខ័ណ្ឌដ៏សំខាន់ ជំរុញក្រុមហ៊ុន Huawei ធ្វើការសម្រេចចិត្តបណ្តាក់ទុនវិនិយោគក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ ហើយបានចាប់យកនូវកាលានុវត្តន៍ភាពវិនិយោគថ្មីៗបន្ថែមទៀតនៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការសម្រេចបង្កើតការិយាល័យថ្នាក់តំបន់របស់ខ្លួនប្រចាំកម្ពុជា។ **លោក Lin Baifeng** ក៏បានសម្តែងនូវក្តីរីករាយ ដែលក្រុមហ៊ុនបានចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យឌីជីថល និងបច្ចេកវិទ្យាទំនើប និងបានប្តេជ្ញាបន្តចូលរួមបណ្តុះបណ្តាលធនធានមនុស្សផ្នែកបច្ចេកវិទ្យា ឱ្យបានច្រើនថែមទៀត ដើម្បីធានាឱ្យបាននូវភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារតំបន់ និងពិភពលោក។

ជាការឆ្លើយតប **សម្តេចបវរធិបតី** បានថ្លែងអំណរគុណចំពោះ ក្រុមហ៊ុន Huawei ដែលតែងតែមានទំនុកចិត្តក្នុងការបណ្តាក់ទុនវិនិយោគ នៅប្រទេសកម្ពុជាអស់រយៈពេល២៥ឆ្នាំកន្លងមកនេះ និងបានសម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន Huawei ចំពោះការបណ្តុះបណ្តាលធនធានមនុស្សផ្នែកឌីជីថល និងបច្ចេកវិទ្យាទំនើបដែលការណ៍នេះជាការរួមចំណែក ដ៏សំខាន់ដល់ការអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលផ្តោតសំខាន់ទៅលើការកសាងមូលធនមនុស្សប្រកបដោយជំនាញ ចំណេះ និងធានាបាននូវផលិតភាពការងារខ្ពស់ សំដៅប្រែក្លាយប្រទេសកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ច និងសង្គម ឌីជីថល ក៏ដូចជារដ្ឋាភិបាលឌីជីថល ស្របទៅតាមការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងយុគសម័យឌីជីថល។/៩

**សម្តេចមហាបវរធិបតី** និងលោក **Lin Baifeng** ក៏បានពិភាក្សាអំពីគំនិតផ្តួចផ្តើមស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យា និងឌីជីថលថ្នាក់តំបន់មួយ ដើម្បីទាក់ទាញអ្នកសិក្សាផ្នែកបច្ចេកវិទ្យាក្នុងតំបន់មកសិក្សានៅកម្ពុជា ក៏ដូចជាការលើកទឹកចិត្តដល់យុវជនកម្ពុជាចាប់យកជំនាញឌីជីថល សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។

ថ្ងៃពុធ ៦រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤